ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើ ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់អ៊ីនធឺណិត រវាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

នារសៀលថ្ងៃសុក្រ ៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (**ក.ដ.ន.ស.**) **ឯកឧត្តម សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក.ដ.ន.ស.** និង **ឯកឧត្តម ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** (**ក.ប.ទ.**) បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើ **ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh** ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់អ៊ីនធឺណិត រវាងក្រសួងទាំងពីរ ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃ **ក.ដ.ន.ស.** និង **ក.ប.ទ.** ជាច្រើនរូប។

អនុស្សរណៈនៃការយោគយល់ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលបំណង ៤ សំខាន់ គឺ ១) ដាក់ឱ្យប្រើ **ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh** សម្រាប់ផ្ទៀងផ្ទាត់ឯកសាររបស់ **ក.ដ.ន.ស.** ដែលមានដាក់បញ្ចូល QR Code ស្តង់ដា ២) រៀបចំប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ដាក់ឱ្យដំណើរការក្នុង **ក.ដ.ន.ស.** ៣) រៀបចំហេដ្ឋារចនាសម្ព័ន្ធនិងការតភ្ជាប់អ៊ីនធឺណិតសម្រាប់ការប្រើប្រាស់ក្នុង **ក.ដ.ន.ស.** និង ៤) សហការរៀបចំថ្នាលបច្ចេកវិទ្យាឌីជីថលដើម្បីចូលរួមអភិវឌ្ឍវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ទាំងអស់នេះ គឺជាសកម្មភាពការងារអាទិភាព ដើម្បីជំរុញល្បឿននៃការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ និងបញ្ចកោណទី៥ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ កិច្ចសហប្រតិបត្តិការនៃការដាក់ឱ្យប្រើ **ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh** នៅលើឯកសាររបស់ **ក.ដ.ន.ស.** នាថ្ងៃនេះ គឺជាជំហានថ្មីមួយទៀត ដែលបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាចំពោះប្រជាពលរដ្ឋ តាមរយៈការកសាងរដ្ឋាភិបាលឌីជីថល សំដៅធានាដល់ការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ។

ឆ្លៀតក្នុងឱកាសនៃពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងទាំងពីរនេះដែរ **ឯកឧត្តម សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក.ដ.ន.ស.** និង **ឯកឧត្តម ជា វ៉ាន់ដេត រដ្ឋមន្ត្រី ក.ប.ទ.** ក៏បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវ **"ថ្នាលកម្ពុជាមាតុភូមិខ្ញុំ (cmhl.gov.kh)"** ដែលអាចចាត់ទុកបានថាជា **ផែនទីជាតិឌីជីថល** ដែលបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក.ដ.ន.ស.** និងដោយមានការគាំទ្របច្ចេកទេសពី **ក.ប.ទ.**។ **ថ្នាលកម្ពុជាមាតុភូមិខ្ញុំ** នឹងអនុញ្ញាតឱ្យក្រសួង ស្ថាប័នទាំងអស់ អាចយកទៅប្រើប្រាស់ និងដាក់បញ្ចូលព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងទីតាំងភូមិសាស្ត្រ និងព័ត៌មាននានាទៅតាមវិស័យរបស់ក្រសួង ស្ថាប័ននីមួយៗ ហើយព័ត៌មានទាំងអស់ដែលមាននៅលើផែនទីជាតិឌីជីថលនេះ នឹងអាច

យកមកប្រើប្រាស់ក្នុងការវិភាគនិងការសិក្សារៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ព្រមទាំងអាចប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនានាផងដែរ។ ជាឧទាហរណ៍ នៅក្នុងវិស័យទូរគមនាគមន៍ គឺ **ក.ប.ទ.** អាចបញ្ចូលទិន្នន័យស្ថានីយអង់តែនទូរគមនាគមន៍ទៅក្នុង **ថ្នាលកម្ពុជាមាតុភូមិខ្ញុំ** ហើយយើងអាចដឹងថា នៅក្នុងឃុំ ស្រុក ឬខេត្តនីមួយៗ មានស្ថានីយអង់តែនទូរគមនាគមន៍ ចំនួនប៉ុន្មាន និងមានទីតាំងនៅកន្លែងណាខ្លះ។

ទន្ទឹមនឹងនេះដែរ ក្រុមការងារបច្ចេកទេសនៃ **ក.ដ.ន.ស.** និង **ក.ប.ទ.** បាននិងកំពុងសហការគ្នារៀបចំដាក់បញ្ចូល QR Code ស្តង់ដា នៅលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលអាចអនុញ្ញាតឱ្យធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មាននៅលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ តាមរយៈ **ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh** និងអាចមើលឃើញអំពីទីតាំងក្បាលដីនោះនៅលើ **ថ្នាលកម្ពុជាមាតុភូមិខ្ញុំ**។

**ក.ដ.ន.ស.** និង **ក.ប.ទ.** មានជំនឿយ៉ាងមុតមាំថា **ថ្នាលកម្ពុជាមាតុភូមិខ្ញុំ** នឹងជួយឱ្យប្រជាពលរដ្ឋនិងធុរជនទទួលបានព័ត៌មានពាក់ព័ន្ធនឹងទីតាំងភូមិសាស្ត្រ និងព័ត៌មានតាមវិស័យនានា បានគ្រប់ជ្រុងជ្រោយប្រកបដោយភាពងាយស្រួល និងភាពជឿទុកចិត្តបាន ហើយគ្រប់ក្រសួង ស្ថាប័ន ក៏មានភាពងាយស្រួលក្នុងការគ្រប់គ្រងព័ត៌មាននានាដែលពាក់ព័ន្ធនឹងវិស័យរបស់ខ្លួនផងដែរ។

សូមបញ្ជាក់ផងដែរថា **ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh** គឺជាថ្នាលរបស់រាជរដ្ឋាភិបាល ដែលអភិវឌ្ឍដោយ **ក.ប.ទ.** និងត្រូវបានដាក់ឱ្យប្រើក្នុងគោលបំណងលុបបំបាត់ការក្លែងបន្លំឯកសារ ផ្តល់ភាពងាយស្រួលក្នុងការប្រើ និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ផ្តល់ទំនុកចិត្ត ចំណេញពេលវេលា និងកាត់បន្ថយចំណាយនានា ព្រមទាំងជំរុញការធ្វើបរិវត្តកម្មឌីជីថល ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ការផ្ទៀងផ្ទាត់ឯកសារនៅលើ **ថ្នាល verify.gov.kh** ត្រូវធ្វើឡើងតាមរយៈការដាក់បញ្ចូល QR Code ស្តង់ដា ដោយប្រើបច្ចេកវិទ្យាប្លុកឆេន (Blockchain) ដែលមានសុវត្ថិភាពខ្ពស់នៅលើសន្លឹកនៃឯកសារនីមួយៗ។ ទន្ទឹមនឹងនេះ ការប្រើឯកសារដែលមានដាក់បញ្ចូល QR Code ស្តង់ដានេះ **មិនតម្រូវឱ្យមានការធ្វើនីត្យានុកូលកម្ម លើឯកសារថតចម្លងក្នុងទម្រង់ជាក្រដាសឡើយ**។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែធ្នូ ឆ្នាំ២០២៣

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | **ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**